ASEAN Capital Markets Forum

វេទិកាទីផ្សារមូលធនអាស៊ាន

ឧបត្ថម្ភដោយ

ADB

ធនាគារអភិវឌ្ឍន៍អាស៊ី

របាយការណ៍ពិសេស វេទិកាទីផ្សារមូលធនអាស៊ាន

រាជធានីភ្នំពេញ ប្រទេសកម្ពុជា

# ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ វេទិកាទីផ្សារមូលធនអាស៊ាន (ACMF) ក្រោមភាពជាប្រធាននៃនិយ័តករមូលបត្រកម្ពុជា បានសម្ពោធដាក់ឱ្យប្រើប្រាស់នូវស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន (ASEAN SLB Standards) ដើម្បីជួយសម្រួលដល់ការប្រមូលសាច់ប្រាក់របស់ក្រុមហ៊ុនដែលរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ខណៈពេលដែល ACMF បន្តសង្កត់ធ្ងន់លើការអភិវឌ្ឍហិរញ្ញវត្ថុនិរន្តរភាពនៅក្នុងតំបន់។

ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាព អាស៊ានគឺជាការអនុម័តចុងក្រោយបំផុតនៃស្តង់ដាសញ្ញាបណ្ណក្នុងក្របខណ្ឌអាស៊ាន ដែលរួមមានស្តង់ដាសញ្ញាបណ្ណបៃតងអាស៊ាន ស្តង់ដាសញ្ញាបណ្ណសង្គមអាស៊ាន និងស្តង់ដាសញ្ញាបណ្ណនិរន្តរភាពអាស៊ានដែលត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៧ និង ២០១៨។

គិតត្រឹមថ្ងៃទី២១ ខែតុលា ឆ្នាំ ២០២២ សញ្ញាបណ្ណ និង Sukuk មានទឹកប្រាក់ទំហំ ២៩,៨២ប៊ីលានដុល្លារអាមេរិកត្រូវបានបោះផ្សាយក្រោមស្តង់ដា និងស្លាកសញ្ញាសញ្ញាបណ្ណបៃតងអាស៊ាន សញ្ញាបណ្ណសង្គមអាស៊ាន និងសញ្ញាបណ្ណនិរន្តរភាពអាស៊ាន ដែលនេះសរឱ្យឃើញថាសញ្ញាបណ្ណប្រភេទនេះ បាននិងកំពុងទទួលបានការចាប់អារម្មណ៍គួរឱ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។

តើអ្វីទៅជាស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន?

ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន គឺជាប្រភេទឧបករណ៍ហិរញ្ញវត្ថុមួយដែលមានលក្ខណៈហិរញ្ញវត្ថុនិង/ឬរចនាសម្ព័ន្ធអាចប្រែប្រួលអាស្រ័យលើថាតើក្រុមហ៊ុនបោះផ្សាយសម្រេចបាននូវគោលបំណងនិរន្តរភាព ដែលបានកំណត់ទុកជាមុន ដែរឬទេ? ឧទាហរណ៍អត្រាគូប៉ុងអាចកើនឡើងបន្ទាប់ពីរយៈពេលកំណត់ជាក់លាក់ណាមួយ ប្រសិនបើគោលដៅនិរន្តរភាពដែលកំណត់ដោយក្រុមហ៊ុនបោះផ្សាយមិនអាចសម្រេចបាន។ គោលដៅនេះត្រូវបានវាស់វែងតាមរយៈសូចនាករគន្លឹះ (KPIs) និងត្រូវបានវាយតម្លៃដោយធៀបនឹងគោលដៅនៃការអនុវត្តប្រកបដោយនិរន្តរភាព (SPTs)។

| លក្ខណៈពិសេសបន្ថែមសំខាន់ៗនៃស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន | | |
|---|---|---|
| | បុគ្គលដែលអាចបោះផ្សាយ | ដើម្បីបង្កើតចំណាត់ថ្នាក់ទ្រព្យសកម្មប្រកបដោយនិរន្តរភាពសម្រាប់តំបន់អាស៊ាន ក្រុមហ៊ុនបោះផ្សាយ ឬការបោះផ្សាយសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពត្រូវតែមានទំនាក់ទំនងភូមិសាស្ត្រ ឬសេដ្ឋកិច្ចក្នុងតំបន់នោះ។ |
| | លទ្ធភាពទទួលបានព័ត៌មានជាបន្តបន្ទាប់ | ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន បានកំណត់បន្ថែមទៀតពីរបៀបដែលវិនិយោគិនត្រូវផ្តល់សិទ្ធិចូលប្រើប្រាស់ព័ត៌មានជាបន្តបន្ទាប់ ដោយតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយត្រូវបង្ហាញព័ត៌មានស្តីពីសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន ក៏ដូចជាត្រូវធានាថាព័ត៌មានទាំងនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈក្នុងគេហទំព័រដែលកំណត់ដោយក្រុមហ៊ុនបោះផ្សាយ។ |
| | ស្តង់ដាលើកទឹកចិត្តការរាយការណ៍ញឹកញាប់ | បន្ថែមលើការរាយការណ៍ប្រចាំឆ្នាំក្រុមហ៊ុនបោះផ្សាយត្រូវបានលើកទឹកចិត្តឱ្យផ្តល់នូវរបាយការណ៍សមាយិកឱ្យទៀងទាត់ ដែលនឹងបង្កើនតម្លាភាពនិងទំនុកចិត្តដល់វិនិយោគិនចំពោះសញ្ញាបណ្ណផ្សារភ្ជាប់ដោយនិរន្តរភាពអាស៊ាន។ |
| | បង្កើនតម្លាភាពកាលវិភាគនៃការរាយការណ៍ | ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណត្រូវបានលើកទឹកចិត្តឱ្យបង្ហាញពីពេលវេលាក្នុងការផ្សព្វផ្សាយរបាយការណ៍ស្តីពីសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន។ |
| | ការត្រួតពិនិត្យខាងក្រៅ | ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណ ត្រូវតែងតាំងអ្នកត្រួតពិនិត្យខាងក្រៅដើម្បីពិនិត្យមើលក្របខណ្ឌសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពរបស់ខ្លួន។ ដោយពិចារណាលើដំណាក់កាលចាប់ផ្តើម នៃការអភិវឌ្ឍទីផ្សារសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពនៅអាស៊ាន អ្នកត្រួតពិនិត្យខាងក្រៅគួរតែមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធនឹងផ្នែក ឬវិស័យដែលពួកគេកំពុងពិនិត្យ។ |
| | លើកទឹកចិត្តឱ្យមានការកំណត់ KPIs ស្របជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព | ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណត្រូវបានលើកទឹកចិត្តឱ្យកំណត់ KPIs ស្របជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ |

ផ្ទុយពីសញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម និង សញ្ញាបណ្ណនិរន្តរភាព ចំពោះសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ ត្រូវតែប្រើប្រាស់សម្រាប់គម្រោងបៃតង សង្គម និងនិរន្តរភាព ការបោះផ្សាយសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាចប្រើប្រាស់ក្នុងគោលបំណងទូទៅបាន។ សញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាព អាចជួយដល់ក្រុមហ៊ុនដែលកំពុងស្វែងរកការផ្លាស់ប្តូរឆ្ពោះទៅរកនិរន្តរភាព។




ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ានត្រូវបានអភិវឌ្ឍដោយផ្អែកលើគោលការណ៍សញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាព (SLBP) របស់សមាគមទីផ្សារមូលធនអន្តរជាតិ (ICMA) ដោយសារតែគោលការណ៍នេះត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងប្រើប្រាស់យ៉ាងទូលំទូលាយ។ SLBP ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាលើកដំបូងនៅក្នុងខែមិថុនា ឆ្នាំ ២០២០ គឺជាសំណុំនៃគោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ដែលអភិវឌ្ឍន៍ដោយអ្នកចូលរួមក្នុងទីផ្សារសំខាន់ៗ ក្រោមការសម្របសម្រួលរបស់ ICMA ជាលេខាធិការដ្ឋាន។

ខណៈពេលដែល SLBP កំណត់នូវគោលការណ៍ទូលំទូលាយចំពោះសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាព ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ានមានគោលបំណងផ្តល់នូវការណែនាំជាក់លាក់បន្ថែមទៀតអំពីរបៀបដែល SLBP ត្រូវអនុវត្តនៅទូទាំងអាស៊ាន។ ក្នុងន័យនេះ ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណ ដែលមានបំណងបោះផ្សាយ និងដាក់ស្លាកសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន ត្រូវតែអនុលោមតាមស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន។

ដូច្នេះ ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាននឹងផ្តល់ទំនុកចិត្តដល់វិនិយោគិន ដោយហេតុថាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាព ដែលត្រូវបានដាក់ស្លាកជាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន បានបំពេញតាមស្តង់ដារួមមួយ ខណៈដែលស្តង់ដានេះនឹងផ្តល់ដល់ក្រុមហ៊ុនបោះផ្សាយ នូវការអនុវត្តល្អបំផុតក្នុងទីផ្សារសម្រាប់សញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាព។

ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន រួមបញ្ចូលនូវធាតុផ្សំស្នូលទាំងប្រាំនៃ SLBP មានដូចជា ការជ្រើសរើស KPIs ការកំណត់ SPTs លក្ខណៈសម្បត្តិរបស់សញ្ញាបណ្ណ ការរាយការណ៍ និងការផ្ទៀងផ្ទាត់ ជាមួយនឹងលក្ខណៈពិសេសបន្ថែមសំខាន់ៗ។

នៅទូទាំងពិភពលោក ទីផ្សារសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពបានរីកចម្រើនយ៉ាងឆាប់រហ័សចាប់តាំងពីការដាក់ឱ្យអនុវត្តនូវ SLBP។ ក្នុងរបាយការណ៍ឆមាសទី១ ឆ្នាំ២០២២ របស់គំនិតផ្តួចផ្តើមសញ្ញាបណ្ណអាកាសធាតុ (Climate Bonds Initiative) បានកត់ត្រាទំហំទឹកប្រាក់នៃការបោះផ្សាយសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពចំនួន ១៧៦,៦ ប៊ីលានដុល្លាអាមេរិក។ សម្រាប់ក្រុមហ៊ុនបោះផ្សាយដែលមិនមានគម្រោងដែលអាចកំណត់បានពីនិរន្តរភាព សញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពគឺជាប្រកក្នុងការប្រមូលហិរញ្ញប្បទានសម្រាប់គោលបំណងទូទៅខណៈដែលគម្រោងនេះក៏រួមចំណែកឆ្ពោះទៅរកគោលដៅនិរន្តរភាព។

ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ានមានគោលបំណងពង្រឹងតម្លាភាព ស្ថិរភាព និងភាពរួមមួយនៃសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពដែលនឹងរួមចំណែកដល់ការអភិវឌ្ឍចំណាត់ថ្នាក់ទ្រព្យសកម្មថ្មី កាត់បន្ថយការចំណាយលើការវាយតម្លៃ និងជួយវិនិយោគិនធ្វើការសម្រេចចិត្តវិនិយោគប្រកបដោយការយល់ដឹងខ្ពស់។

ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន អាចទាញយកបានតាមរយៈ៖ https://www.theacmf.org/initiatives/sustainable-finance/asean-sustainability-linked-bond-standards។ ■

# ស្តង់ដាមូលនិធិនិរន្តរភាព និងទំនួលខុសត្រូវអាស៊ាន (ASEAN SRFS)

ដោយមូលធនភាគច្រើនត្រូវបានតម្រង់ឆ្ពោះទៅរកការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs) ជាសកល និងគោលដៅអាកាសធាតុ ទើបមូលនិធិនិរន្តរភាពសកល បាននិងកំពុងពង្រីកខ្លួនយ៉ាងខ្លាំង។ ទំហំនៃមូលនិធិនិរន្តរភាពជាសកល បានឈានដល់ ២,៧ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២១ ដែលកើនឡើងពី ១៩៥ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០១០ ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំ (CAGR) ២៧%។ មូលនិធិចំនួន ១.៣០៤ ក្នុងឆ្នាំ២០១០ បានកើនដល់ ៥.៩៣២ ក្នុងឆ្នាំ ២០២១ ហើយចំនួនសរុបនៃមូលនិធិនិរន្តរភាពបានកើនឡើង CAGR ចំនួន ១៥% ក្នុងរយៈពេលដូចគ្នានេះ ។

ជាមួយគ្នានេះដែរ ដោយការវិនិយោគប្រកបដោយនិរន្តរភាពបានទទួលនូវការចាប់អារម្មណ៍កាន់តែច្រើននៅក្នុងតំបន់អាស៊ាន និងដោយស្របតាមអនុសាសន៍អំពីផលិតផលកាតាលីករ និងការអនុញ្ញាតឱ្យចូលទៅកាន់តំបន់/ផ្នែកដែលមិនទាន់បានផ្គត់ផ្គង់គ្រប់គ្រាន់នៃផែនទីបង្ហាញផ្លូវទីផ្សារមូលធននិរន្តរភាពអាស៊ាន ASEAN SRFS ត្រូវបានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ដោយ ACMF ដើម្បីពង្រីកវិសាលភាពនៃការវិនិយោគប្រកបដោយនិរន្តរភាពនៅក្នុងអាស៊ាន។

ASEAN SRFS មានគោលបំណងផ្តល់នូវលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មាន និងការរាយការណ៍ជាអប្បបរមា ដែលតម្រូវឱ្យអនុវត្តជាប់លាប់សម្រាប់គម្រោងវិនិយោគរួម (Collective Investment Schemes - CIS) ដែលស្នើសុំជា ASEAN SRFS ដោយសារតែមានការកើនឡើងនៃ CIS ដែលផ្តោតលើការវិនិយោគ ESG និងតម្រូវការសម្រាប់ការប្រៀបធៀប, ភាពរួមតែមួយ និងការបង្ហាញព័ត៌មាន ប្រកបដោយតម្លាភាព ដើម្បីកាត់បន្ថយហានិភ័យនៃការក្លែងបន្លំភាពបៃតង (greenwashing) ព្រមទាំងជួយវិនិយោគិនក្នុងការសម្រេចចិត្តលើការវិនិយោគឱ្យបានត្រឹមត្រូវ។

ក្នុងន័យនេះ CIS ឬប្រតិបត្តិករ CIS ត្រូវតែអនុលោមតាម ASEAN SRFS ដែលផ្តល់នូវការបង្ហាញព័ត៌មានបន្ថែមនៃ CIS ដែលមានលក្ខណៈគុណវឌ្ឍិគ្រប់គ្រាន់។

**លក្ខណៈសំខាន់នៃ ASEAN SRFS**

**ក) ការដាក់ឈ្មោះ**

ឈ្មោះរបស់CISដែលមានលក្ខណៈគុណវឌ្ឍិគ្រប់គ្រាន់គួរតែមានភាពត្រឹមត្រូវឆ្លុះបញ្ចាំងពីធាតុប្រកបដោយនិរន្តរភាពរបស់ CIS ដោយមិនបញ្ជាក់ ឬសង្កត់ធ្ងន់លើសពីធាតុប្រកបដោយនិរន្តរភាព ឬធ្វើឱ្យមានការយល់ច្រឡំ។

**(ខ) យុទ្ធសាស្ត្រ និងគោលបំណងវិនិយោគប្រកបដោយនិរន្តរភាព**

CIS គួរតែវិនិយោគជាចម្បងលើមូលបត្រដោយអនុលោមតាមយុទ្ធសាស្ត្រនិងគោលបំណងវិនិយោគប្រកបដោយនិរន្តរភាព ជាមួយនឹងការបែងចែកទ្រព្យសកម្មអប្បបរមាយ៉ាងហោចណាស់ពីរភាគបី (២/៣) នៃតម្លៃទ្រព្យសកម្មសុទ្ធ។ ឧទាហរណ៍៖ គោលការណ៍ និងយុទ្ធសាស្ត្រវិនិយោគនិរន្តរភាព ត្រូវបានបញ្ចូលនៅក្នុង ASEAN SRFS ជាការណែនាំ។ ទោះជាយ៉ាងណាក៏ដោយសម្រាប់ CIS ដែលគ្រាន់តែអនុវត្តនូវយុទ្ធសាស្ត្រសមាហរណកម្ម ESG ឬយុទ្ធសាស្ត្រត្រួតពិនិត្យលើភាពអវិជ្ជមាន ដើម្បីស្វែងរកប្រាក់ចំណូលផ្នែកហិរញ្ញវត្ថុដោយមិនមានគោលបំណងវិនិយោគប្រកបដោយនិរន្តរភាពនោះទេ គឺមិនមានគុណវឌ្ឍិគ្រប់គ្រាន់ជា ASEAN SRFS។

**(គ) នីតិវិធី និងគោលនយោបាយដើម្បីធានាបាននូវអនុលោមភាព**

ASEAN SRFS តម្រូវឱ្យបង្ហាញព័ត៌មានអំពីដំណើរការដើម្បីធានាបាននូវអនុលោមភាពនៃ ASEAN SRFS របស់ CIS ពេញមួយវដ្តនៃ CIS។

**(ឃ) ការផ្ទៀងផ្ទាត់ដោយភាគីទីបី**

ការផ្ទៀងផ្ទាត់ដោយភាគីទីបីអាចធ្វើឡើងតាមការស្ម័គ្រចិត្ត ដើម្បីផ្ទៀងផ្ទាត់ថាការវិនិយោគរបស់ CIS ស្របតាមយុទ្ធសាស្ត្រ និងគោលបំណងវិនិយោគប្រកបដោយនិរន្តរភាពរបស់ខ្លួន។

**(ង) របាយការណ៍សមាយិក**

CIS ឬប្រតិបត្តិករ CIS ត្រូវបានតម្រូវឱ្យផ្តល់ព័ត៌មានទាក់ទងនឹងយុទ្ធសាស្ត្រនិងគោលបំណងវិនិយោគប្រកបដោយនិរន្តរភាពរបស់ CIS ក៏ដូចជាការពិនិត្យឡើងវិញលើការពិចារណានិរន្តរភាព នៅក្នុងរបាយការណ៍សមាយិក ឬរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន តាមដែលអាចអនុវត្តបាន ហើយអាចផ្សព្វផ្សាយបាននៅលើគេហទំព័រ។ បន្ថែមលើនេះទៀត ឥទ្ធិពលនៃយុទ្ធសាស្ត្រវិនិយោគរបស់ CIS ក៏ត្រូវបានតម្រូវឱ្យចេញផ្សាយរបាយការណ៍ផលប៉ះពាល់ប្រចាំឆ្នាំផងដែរ។

**(ច) ការដកហូតគុណវុឌ្ឍិ**

CIS ឬប្រតិបត្តិករ CIS ត្រូវតែផ្តល់ព័ត៌មានពាក់ព័ន្ធ ជាពិសេសព័ត៌មាន ឬព្រឹត្តិការណ៍សំខាន់ដែលធ្វើឱ្យប៉ះពាល់ដល់អនុលោមភាពតាម ASEAN SRFS និងអនុលោមភាពតាមបទប្បញ្ញត្តិរបស់និយ័តករមូលបត្រនៅក្នុងយុត្តាធិការអាស៊ាន។ នៅពេលដែល CIS ត្រូវបានរកឃើញថាមិនបានអនុលោមតាម ASEAN SRFS និយ័តករមូលបត្រអាចដកហូតគុណវុឌ្ឍិរបស់ CIS បាន។

ការប្រើប្រាស់និរន្តរភាពសម្រាប់កំណើននាពេលអនាគតការវិនិយោគប្រកបដោយនិរន្តរភាព មានសារៈសំខាន់ក្នុងការពន្លឿនដំណើរឆ្ពោះទៅរកការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់កម្រិតសូន្យ (net zero) ជាសកល។ ទីផ្សារវិនិយោគប្រកបដោយនិរន្តរភាពពិភពលោក ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១៦០ ទ្រីលានដុល្លារអាមេរិកត្រឹមឆ្នាំ២០៣៦។ ទីផ្សារគ្រប់គ្រងមូលនិធិ និងទ្រព្យសកម្មនៅក្នុងតំបន់អាស៊ាន ត្រូវតែទាញយកប្រយោជន៍ពីនិន្នាការទាំងនេះ ហើយត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីឱ្យវិនិយោគិនទទួលបាននូវជម្រើសកាន់តែច្រើនសម្រាប់ការវិនិយោគប្រកបដោយនិរន្តរភាព។ ករណីនេះតម្រូវឱ្យមានការបង្កើតឡើងនូវផលិតផលមូលនិធិប្រកបដោយនិរន្តរភាពប្រកបដោយនវានុវត្តន៍បន្ថែមទៀតដើម្បីបំពេញតម្រូវការ និងផលប្រយោជន៍របស់វិនិយោគិន។

នៅពេលដែលមូលនិធិប្រកបដោយនិរន្តរភាពសកលលោកមានការវិវត្តន៍កាន់តែលឿន នោះតម្រូវការនៃការបង្ហាញព័ត៌មានលម្អិត និងទៀងទាត់ក៏ដូចជាការរៀបចំវិធានការដើម្បីកាត់បន្ថយបញ្ហាការក្លែងបន្លំភាពបៃតង ក៏មានការកើនឡើងផងដែរ។

អាស្រ័យហេតុនេះ ASEAN SRFS មានគោលបំណងផ្តល់នូវមូលដ្ឋានជាអប្បបរមាអំពីលក្ខខណ្ឌតម្រូវនៃការរាយការណ៍ និងការបង្ហាញព័ត៌មានរបស់មូលនិធិប្រកបដោយនិរន្តរភាពដែលត្រូវបោះផ្សាយលក់នៅក្នុងតំបន់អាស៊ាន ដែលវាជួយបង្កើននូវតម្លាភាព និងភាពស៊ីសង្វាក់គ្នានៃព័ត៌មានដល់វិនិយោគិន។

ស្តង់ដាមូលនិធិនិរន្តរភាព និងទំនួលខុសត្រូវអាស៊ាន អាចទាញយកបានតាមរយៈ

https://www.theacmf.org/initiatives/sustainable-finance/asean-sustainable-and-responsible-fund-standards. ■




ASEAN SRFS **តម្រង់ឆ្ពោះទៅរកការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។** រូបថត Supplied

# ទីផ្សារសញ្ញាបណ្ណបៃតងសង្គម និង និរន្តរភាពអាស៊ាន (GSS)

គិតមកដល់ពេលនេះគឺមានរយៈ-ពេល ៥ឆ្នាំហើយដែលនិយ័តករមូល-បត្រអាស៊ានបានខិតខំជំរុញនូវការ-អភិវឌ្ឍហិរញ្ញវត្ថុនិរន្តរភាពនៅក្នុងតំបន់។ ក្រុមការងារហិរញ្ញវត្ថុបៃតងនៃវេទិកាទីផ្សារមូលធនអាស៊ាន (ACMF) បានរៀបចំសេចក្តីព្រាងនិងដាក់ចេញនូវគំនិតផ្តួចផ្តើមហិរញ្ញ-វត្ថុនិរន្តរភាពដំបូងរបស់ខ្លួនគឺស្តង់ដាសញ្ញាបណ្ណបៃតងអាស៊ានក្នុងរយៈពេលតិចជាងមួយឆ្នាំ។ ក្នុងឆ្នាំ២០១៨ ស្តង់ដាសញ្ញាបណ្ណសង្គមអាស៊ាន និងស្តង់ដាសញ្ញាបណ្ណនិរន្តរភាពអាស៊ានត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់បន្ទាប់ពីការអនុម័តដាក់ឱ្យប្រើប្រាស់ស្តង់ដាសញ្ញាបណ្ណបៃតងអាស៊ាន។

នាពេលបច្ចុប្បន្ននេះ ប្រទេសអាស៊ានចំនួន៥រួមមាន៖ ប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ កំពុងគ្រប់គ្រងទីផ្សារសញ្ញាបណ្ណ-បៃតងសង្គម និងនិរន្តរភាពអាស៊ាន (GSS)។ យោងតាមទិន្នន័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ខែកញ្ញា ឆ្នាំ២០២២ ប្រទេសសិង្ហបុរីជាប្រទេសដែលមានការបោះផ្សាយលក់សញ្ញាបណ្ណបៃតងសង្គម និងនិរន្តរភាពអាស៊ានដោយក្រុមហ៊ុនក្នុងស្រុក និងក្នុងតំបន់ច្រើនជាងគេដែលមានទឹកប្រាក់ប្រមាណជា ១០,៧ ប៊ីលានដុល្លារអាមេរិក។ ខណៈដែលប្រទេសឥណ្ឌូនេស៊ីជាប់ចំណាត់ថ្នាក់លេខពីរនៅក្នុងការបោះផ្សាយលក់ GSS ដែលមានទឹកប្រាក់ប្រមាណជា ៩,១ប៊ីលានដុល្លារអាមេរិក។ ចំពោះការបោះផ្សាយលក់ GSS នៅក្នុងប្រទេសថៃមានចំនួនទឹកប្រាក់ ៦,៥ ប៊ីលានដុល្លារអាមេរិក ហើយជាប្រទេសដែលមានទីផ្សារសញ្ញាបណ្ណនិរន្តរភាពរូបិយបណ្ណក្នុងស្រុកដ៏ធំបំផុតដែលមានទំហំទឹកប្រាក់ ២,៦ ប៊ីលានដុល្លារនៃសញ្ញាបណ្ណ GSS។ ប្រទេសម៉ាឡេស៊ី មានសញ្ញាបណ្ណ GSS ដែលមានតម្លៃជិត ៦ប៊ីលានដុល្លារដែលបានបោះផ្សាយជារូបិយបណ្ណបរទេសនិងក្នុងស្រុកដោយរដ្ឋាភិបាល និងវិស័យឯកជន។ ប្រទេសហ្វីលីពីនមានសញ្ញាបណ្ណនិរន្តរភាពដែលមានតម្លៃ ៦,៩៤ ប៊ីលានដុល្លារអាមេរិក ដែលបានបោះផ្សាយដោយក្រុមហ៊ុនបោះផ្សាយឯកជនជាច្រើនក្នុងចំណោមក្រុមហ៊ុនដទៃផ្សេងទៀត រួមមានធនាគារសហគ្រាសថាមពលកកើតឡើងវិញ (Renewable Energy Firms)។

កំណើនទីផ្សារបំណុលនិរន្តរភាពអាស៊ានដ៏គួរឱ្យកត់សម្គាល់ក្នុងរយៈ-ពេល ៥ឆ្នាំចុងក្រោយនេះ បង្ហាញយ៉ាងច្បាស់ថាទោះជាអាស៊ានជាតួអង្គដ៏តូចមួយនៅក្នុងទីផ្សារហិរញ្ញ-វត្ថុនិរន្តរភាពសកល ក៏មូលដ្ឋានគ្រឹះសំខាន់ៗសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្របំណុលបៃតង និងនិរន្តរភាពត្រូវបានបង្កើតឡើងរួចរាល់។

ខណៈពេលដែលរដ្ឋាភិបាលជំរុញកំណើននេះតាមរយៈការពង្រឹងការ-គាំទ្រផ្នែកច្បាប់ និងនិន្នាការតំបន់បង្ហាញថាក្រុមហ៊ុនកាន់តែច្រើនទទួលស្គាល់ពីសារៈសំខាន់និងអត្ថ-ប្រយោជន៍នៃហិរញ្ញវត្ថុនិរន្តរភាព និងរៀបចំនូវយុទ្ធសាស្ត្រអាជីវកម្មដែលឆ្លើយតបនឹងហានិភ័យអាកាសធាតុ។

ក្នុងខែតុលា ឆ្នាំ២០២២ ACMF បានបង្កើត និងដាក់ចេញនូវស្តង់ដាហិរញ្ញវត្ថុនិរន្តរភាពចំនួនពីរ៖ ស្តង់ដា-សញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាព-អាស៊ាន និងស្តង់ដាមូលនិធិទំនួល-ខុសត្រូវ និងនិរន្តរភាពអាស៊ាន ដែលនឹងពង្រីកវិសាលភាពនៃការវិនិយោគប្រកបដោយនិរន្តរភាពនៅក្នុងតំបន់ និងជួយក្នុងការពន្លឿនការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅទូទាំងអាស៊ាន៕




## ការបោះផ្សាយ GSS នៅអាស៊ាន

**ប្រទេសឥណ្ឌូនេស៊ី**

កាលពីខែមីនា ឆ្នាំ២០១៨ រដ្ឋាភិបាលឥណ្ឌូនេស៊ីបានបោះផ្សាយសញ្ញាបណ្ណ Sukuk បៃតងជាលើកដំបូង ដែលនេះក៏ជាសញ្ញាបណ្ណ Sukuk បៃតងដំបូងគេបំផុតបានបោះផ្សាយនៅលើពិភពលោក ក្នុងទំហំទឹកប្រាក់ ១,២៥ប៊ី-លានដុល្លារអាមេរិក ដែលមានឥណប្រតិទានរយៈពេល ៥ឆ្នាំ។ យោងតាមក្របខណ្ឌបទប្បញ្ញត្តិរបស់ប្រទេសឥណ្ឌូនេស៊ី ប្រាក់ដែលបានពីការបោះផ្សាយនេះនឹងប្រើប្រាស់សម្រាប់តែគម្រោងបៃតងផ្នែកថាមពលកកើតឡើងវិញតែប៉ុណ្ណោះ។ ចាប់តាំងពីការបោះផ្សាយឆ្នាំ២០១៨ ឥណ្ឌូនេស៊ីបានបោះផ្សាយសញ្ញាបណ្ណនិរន្តរ-ភាពជារៀងរាល់ឆ្នាំ ដោយបានបោះផ្សាយនូវសញ្ញាបណ្ណ Sukuk បៃតងចំនួន ៧៥០លានដុល្លារក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២១ និង ១,៥ប៊ីលានដុល្លារក្នុងខែមិថុនាឆ្នាំ២០២២។

**ប្រទេសម៉ាឡេស៊ី**

ប្រទេសម៉ាឡេស៊ីបាននាំមុខទីផ្សារសញ្ញាបណ្ណបៃតងអាស៊ានក្នុងឆ្នាំ២០១៧ ជាមួយនឹងការ-បោះផ្សាយសញ្ញាបណ្ណបៃតងអាស៊ានដំបូងដោយក្រុមហ៊ុន PNB Merdeka Ventures Sdn Bhd និងសញ្ញាបណ្ណ Sukuk និរន្តរភាពដែលបោះផ្សាយដោយរដ្ឋាភិបាលជាប្រាក់ដុល្លារអាមេរិក ដំបូងបង្អស់របស់ពិភពលោក។ កាលពីខែមេសា ឆ្នាំ២០២១ ម៉ាឡេស៊ីបានដាក់តម្លៃដាយជាគជ័យនូវសញ្ញញាបណ្ណ Sukuk និរន្តរភាពរបស់ខ្លួនដែលមានតម្លៃជាទឹកប្រាក់ ៨០០ លានដុល្លារអាមេរិកនៃវិញ្ញាបនបត្របរ-ធនបាលកិច្ចរយៈពេល ១០ឆ្នាំ។

**ប្រទេសហ្វីលីពីន**

សាជីវកម្មហេដ្ឋារចនាសម្ព័ន្ធ និងថាមពល AC (AC Energy and Infrastructure Corpora-tion) ដែលពីមុនជា AC Energy, Inc. គឺជាក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណបៃតងដ៏ធំបំផុតមួយរបស់ហ្វីលីពីន។ ក្នុងឆ្នាំ២០១៩ ក្រុមហ៊ុននេះបានបង្ហាញខ្លួនជាលើកដំបូងនៅក្នុងទីផ្សារបំណុលជាមួយនឹងការបោះផ្សាយសញ្ញាបណ្ណបៃតងដែលកំណត់ជាប្រាក់ដុល្លារអាមេរិក (USD) សរុបជាទឹកប្រាក់ចំនួន ៤១០លានដុល្លារអាមេរិក ដែលជាសញ្ញាបណ្ណបៃតងជាប្រាក់ដុល្លារអាមេរិកដំបូងបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលបញ្ជាក់ដោយគំនិតផ្តួចផ្តើមសញ្ញាបណ្ណអាកាសធាតុ(Climate Bonds Initiative) ដែលក្រោយមកការបោះផ្សាយនេះបានកើនឡើងដល់ ៤៧០លានដុល្លារអាមេរិក។ នៅក្នុងឆ្នាំដដែល ក្រុមហ៊ុននេះបានបោះផ្សាយបណ្ណបៃតងអចិន្ត្រៃយ៍ដែលកំណត់ជាប្រាក់ដុល្លារអាមេរិកដំបូងគេរបស់ពិភពលោកក្នុងចំនួនទឹកប្រាក់ដើមសរុបចំនួន ៤០០លានដុល្លារអាមេរិក។

ចាប់តាំងពីពេលនោះមក ក្រុមហ៊ុនបានបន្តបោះផ្សាយសញ្ញាបណ្ណបៃតងជារៀងរាល់ឆ្នាំក្នុងគោលបំណងប្រើប្រាស់សម្រាប់ផ្តល់ហិរញ្ញប្ប-ទានថាមពលកកើតឡើងវិញ (renewable energy) ដែលថ្មីៗនេះគឺជាសញ្ញាបណ្ណបៃតងដែលមានអត្រាថេររយៈពេលប្រាំឆ្នាំមានទំហំទឹកប្រាក់ ១០ ប៊ីលានប៉េសូហ្វីលីពីន (PHP) (១៧៦ លានដុល្លារអាមេរិក) ត្រូវបានបោះ-ផ្សាយក្នុងឆ្នាំ២០២២។

**ប្រទេសសិង្ហបុរី**

កាលពីឆ្នាំ២០១៨ ក្រុមហ៊ុន Sindicatum Renewable Energy Company Pte Ltd បានបោះផ្សាយសញ្ញាបណ្ណបៃតងពហុរូបិយបណ្ណបីដែលបានចុះបញ្ជីនៅក្នុងផ្សារហ៊ុនទីក្រុងឡុងដ៍ (LSE)។ នៅខែមករាឆ្នាំ២០១៨ សញ្ញាបណ្ណដែលចារឹកជាប្រាក់រ៉ូពីឥណ្ឌូ (IDR) មានទំហំទឹកប្រាក់ចំនួន ៩៥១,១លានរ៉ូពី និង១.៥៨៥,៣ លានរ៉ូពី ដែលដល់ឥណប្រតិទានឆ្នាំ២០២៣ និង ២០២៥ រៀងគ្នាត្រូវបានបោះផ្សាយ ដែលបានធ្វើឱ្យ Sindicatum Renewables ជាសាជីវកម្មឯកជនដំបូងគេដែលបានបោះផ្សាយសញ្ញាបណ្ណបៃតងដែលចារឹកជារូបិយបណ្ណរ៉ូពីឆ្លងដែន ដែលមានឥណប្រតិទានរយៈពេល៧ ឆ្នាំ។ លើសពីនេះ កាលពីខែវិច្ឆិកា ឆ្នាំ២០១៨ ក្រុមហ៊ុននេះក៏បានបោះផ្សាយសញ្ញាបណ្ណដែលចារឹកជារូបិយបណ្ណប៉េសូហ្វីលីពីន (PHP) មានទំហំទឹកប្រាក់១.០៦០,២ លានប៉េសូហ្វីលីពីន ដែលនឹងដល់ឥណប្រតិទាននៅឆ្នាំ២០២៨ ហើយនេះជាសញ្ញាបណ្ណបៃតងដែលចារឹកជាប្រាក់ប៉េសូហ្វីលីពីន (PHP) ដំបូងដែលបានចុះបញ្ជីនៅ LSE ។

**ប្រទេសថៃ**

កាលពីខែសីហា ឆ្នាំ២០២០ ក្រសួងហិរញ្ញវត្ថុថៃបានក្លាយជារដ្ឋអធិបតេយ្យមួយក្នុងពិភពលោក និងក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលបានប្រមូលមូលនិធិតាមរយៈការបោះផ្សាយសញ្ញាបណ្ណ-និរន្តរភាព។ គិតត្រឹមខែឧសភា ឆ្នាំ២០២២ ក្រសួងបានបោះផ្សាយសញ្ញាបណ្ណនិរន្តរភាពដែលមានតម្លៃជាទឹកប្រាក់ប្រមាណ ៦ប៊ីលានដុល្លារអាមេរិក ដែលត្រូវបានប្រើប្រាស់សម្រាប់វិនិយោគក្នុងគម្រោង Mass Rapid Transit Orange East Line និងគម្រោងផលប៉ះពាល់សង្គម ក្នុងចំណោមគម្រោងផ្សេងៗទៀត។ ការ-បោះផ្សាយនេះបានធ្វើឱ្យព្រះរាជាណាចក្រថៃក្លាយជាស្ថាប័នថៃដំបូងគេដែលបានចុះបញ្ជីនៅផ្សារហ៊ុន Luxembourg។ សញ្ញាបណ្ណទាំងនេះក៏ទទួលបានពានរង្វាន់ពីអង្គភាពផ្សេងៗគ្នាសរុបចំនួន ៦ផងដែរ៕ ■

# សញ្ញាបណ្ណគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពអាស៊ាន

ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅក្នុងអាស៊ាន វេទិកាទីផ្សារមូលធនអាស៊ាន (ACMF) បានដាក់ចេញនូវស្តង់ដាសញ្ញាបណ្ណបៃតង សង្គម និងនិរន្តរភាពអាស៊ាន ដែលអនុវត្តតាមគោលការណ៍សញ្ញាបណ្ណបៃតងសង្គម និងគោលការណ៍ណែនាំសញ្ញាបណ្ណនិរន្តរភាពរបស់សមាគមទីផ្សារមូលធនអន្តរជាតិ (ICMA)។ ដើម្បីជំរុញការបោះផ្សាយសញ្ញាបណ្ណដែលកំណត់ជាក់លាក់សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលជាផ្នែកមួយនៃរបៀបវារៈនិរន្តរភាពក្នុងតំបន់ ក្នុងឆ្នាំ២០២១ ACMF បានដាក់ចេញនូវ "Toolkit សញ្ញាបណ្ណគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDG) អាស៊ាន៖ មគ្គុទេសន៍អនុវត្តសម្រាប់ការបោះផ្សាយសញ្ញាបណ្ណ SDG នៅក្នុងតំបន់អាស៊ាន" ក្នុងគោលបំណងផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការបោះផ្សាយសញ្ញាបណ្ណ SDG នៅក្នុងតំបន់អាស៊ាន។ ដោយទទួលស្គាល់ថាទីផ្សារសញ្ញាបណ្ណ SDG នៅអាស៊ានទើបចាប់បដិសន្ធិឡើង ហើយការអនុវត្តទីផ្សារកំពុងតែវិវឌ្ឍទៅមុខ Toolkit បានកំណត់នូវការណែនាំបឋមលើគោលការណ៍ និងដំណើរការគន្លឹះ ដែលក្រុមហ៊ុនបោះផ្សាយអាចប្រកាន់ខ្ជាប់នៅពេលបោះផ្សាយសញ្ញាបណ្ណ SDG។ គោលការណ៍ និងដំណើរការទាំងនេះ ត្រូវបានរៀបចំឡើងផ្អែកទៅលើឧត្តមានុវត្តន៍នៃការអនុវត្តជាលក្ខណៈអន្តរជាតិ និងបទពិសោធន៍នៃឧទាហរណ៍ជោគជ័យនៃការបោះផ្សាយសញ្ញាបណ្ណ SDG ក្នុងតំបន់អាស៊ាន និងតំបន់ផ្សេងទៀត ក៏ដូចជាតម្រូវការរបស់វិនិយោគិនផងដែរ។ តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ACMF បានអភិវឌ្ឍ Toolkit សញ្ញាបណ្ណ SDG អាស៊ាន សម្រាប់ជាធនធានគន្លឹះសម្រាប់ការកសាងសមត្ថភាព និងការអប់រំទីផ្សារ។ Toolkit គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់របស់ ACMF ដើម្បីពង្រីកចំណេះដឹង និងការយល់ដឹងរបស់អ្នកចូលរួមទីផ្សារអាស៊ានពីនីតិវិធីនៃការបោះផ្សាយសញ្ញាបណ្ណដែលទាក់ទងនឹងហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពឱ្យកាន់តែទូលំទូលាយ។ ជាការបំពេញបន្ថែម Toolkit សញ្ញាបណ្ណ SDG អាស៊ាន និងដើម្បីគាំទ្រដល់ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណ SDG និងវិនិយោគិនសក្តានុពល ដោយមានការគាំទ្រពីវិស័យឯកជន "ធាតុបំពេញបន្ថែម Toolkit នៃសញ្ញាបណ្ណ SDG អាស៊ាន៖ ទិដ្ឋភាពច្បាប់ និងបទប្បញ្ញត្តិសម្រាប់បណ្តាប្រទេសក្នុងតំបន់អាស៊ាន" ត្រូវបានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅក្នុងសន្និសីទអន្តរជាតិ ACMF ដែលទទួលធ្វើជាម្ចាស់ផ្ទះរៀបចំដោយនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ក្នុងនាមជាប្រធាន ACMF ឆ្នាំ២០២២ ក្រោមការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ Toolkit នៃបណ្តាប្រទេសទាំង ១០ អាចទាញយកបានតាមរយៈតំណភ្ជាប់៖ https://www.theacmf.org/initiatives/sustainable-finance/asean-sdg-bond-toolkit-supplement-legal-and-regulatory-aspects--for-asean-countries។




| ការបោះផ្សាយជាលក្ខណៈឯកជន | ការបោះផ្សាយជាសាធារណៈ |
|---|---|
| - ត្រូវធ្វើឡើងចំពោះបុគ្គលមិនលើសពី ៣០នាក់ ក្នុងរយៈពេលមិនលើសពី១២ខែ<br>- មិនត្រូវធ្វើផ្សព្វផ្សាយជាសាធារណៈ រួមទាំងការពិគ្រោះយោបល់ពាក់ព័ន្ធនឹងការវិនិយោគ។<br>- អង្គភាពដែលមានបំណងបោះផ្សាយជាលក្ខណៈឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធជូន ន.ម.ក. ហើយរាយការណ៍លទ្ធផលនៃការបោះផ្សាយជូន ន.ម.ក.។ | - ត្រូវតែជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត<br>- ត្រូវមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល លើការបោះផ្សាយមូលបត្របំណុល<br>- ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់រយៈពេលពីរឆ្នាំចុងក្រោយ<br>- ត្រូវមានអភិបាលកិច្ចសាជីវកម្មរឹងមាំ<br>- ត្រូវធ្វើចំណាត់ថ្នាក់លទ្ធភាពសងដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី ន.ម.ក.<br>- ត្រូវទទួលបានការអនុញ្ញាតជាគោលការណ៍ពី ន.ម.ក. លើការបោះផ្សាយមូលបត្របំណុល។ |

ធាតុបំពេញបន្ថែមនៃ Toolkit ផ្តល់នូវព័ត៌មានបទប្បញ្ញត្តិទាក់ទងនឹងលក្ខខណ្ឌតម្រូវក្នុងការបោះផ្សាយសញ្ញាបណ្ណ SDG ដោយសាជីវកម្ម និងរដ្ឋាភិបាល ក្របខណ្ឌបទប្បញ្ញត្តិដែលសាជីវកម្ម និងរដ្ឋាភិបាលត្រូវអនុវត្តតាម ក៏ដូចជាការលើកទឹកចិត្តសម្រាប់ការបោះផ្សាយ SDG។ សម្រាប់វិនិយោគិន ធាតុបំពេញបន្ថែមនៃ Toolkit ផ្តល់ព័ត៌មានពាក់ព័ន្ធដូចជាសញ្ញាបណ្ណត្រូវបានបោះផ្សាយលក់ជាសាធារណ ឬជាឯកជន និងការលើកទឹកចិត្តសម្រាប់ការវិនិយោគលើសញ្ញាបណ្ណ SDG។ យោងតាមធាតុបំពេញបន្ថែមនៃ Toolkit ប្រទេសទាំង ១០ យើងពិនិត្យឃើញថា ការបោះផ្សាយសញ្ញាបណ្ណ SDG ត្រូវបានលើកទឹកចិត្ត ដោយក្រុមហ៊ុនបោះផ្សាយត្រូវបំពេញតាមក្របខណ្ឌបទប្បញ្ញត្តិនៃការបោះផ្សាយសញ្ញាបណ្ណធម្មតា និងបំពេញតាមលក្ខខណ្ឌនៃស្តង់ដាអាស៊ាន ដើម្បីទទួលបាននូវស្លាក (Labelled) ជាសញ្ញាបណ្ណអាស៊ាន។ ចាប់តាំងពីគំនិតផ្តួចផ្តើមហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពត្រូវបានដាក់ឱ្យដំណើរការនៅក្នុងតំបន់អាស៊ាន រដ្ឋាភិបាល និងនិយ័តករផ្តល់ការគាំទ្រយ៉ាងខ្លាំងក្នុងការបោះផ្សាយសញ្ញាបណ្ណ SDG។ លើសពីនេះទៅទៀត សញ្ញាបណ្ណបៃតង សង្គម និងនិរន្តរភាព ដែលបង្ហាញពី SDG តែក៏អាចនឹងមិនពាក់ព័ន្ធនឹង SDG ផងដែរ បានកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងតំបន់អាស៊ាន។ ក្នុងរយៈពេល ៥ឆ្នាំ ទំហំទឹកប្រាក់នៃការបោះផ្សាយសរុបឈានដល់ ៣១,០៥ប៊ីលានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ដែលក្នុងនោះការបោះផ្សាយសញ្ញាបណ្ណបៃតងមាន៣០% ការបោះផ្សាយសញ្ញាបណ្ណនិរន្តរភាពមាន ៦៤% និងសញ្ញាបណ្ណសង្គមមាន ៦% នៃទំហំបោះផ្សាយសរុប ដោយក្នុងនោះប្រទេសថៃគឺជាប្រទេសឈានមុខគេក្នុងការបោះផ្សាយសញ្ញាបណ្ណ GSS ក្នុងចំណោមប្រទេសម៉ាឡេស៊ី ហ្វីលីពីន និងសិង្ហបុរី។ យើងរំពឹងថាចំនួននេះនឹងកើនឡើងយ៉ាងឆាប់រហ័សក្នុងឆ្នាំបន្ទាប់ ក្រោយការដាក់ឱ្យដំណើរការស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាពអាស៊ាន និងស្តង់ដាមូលនិធិទំនួលខុសត្រូវ និងនិរន្តរភាពអាស៊ាន។

ក្នុងនាមជាប្រធាន ACMF ឆ្នាំ២០២២ និងជាសមាជិកនៃ ACMF ន.ម.ក. តែងគាំទ្រយ៉ាងមោះមុតក្នុងការលើកកម្ពស់ការបោះផ្សាយសញ្ញាបណ្ណដើម្បីគាំទ្រដល់របៀបវារៈនិរន្តរភាព។ ដើម្បីអាចបោះផ្សាយសញ្ញាបណ្ណ SDG នៅកម្ពុជា សាជីវកម្មអាចបោះផ្សាយជាសាធារណៈ និងឯកជន ដោយត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវដូចមានក្នុងតារាង និងអនុវត្តតាមស្តង់ដាសញ្ញាបណ្ណបៃតង សង្គម និរន្តរភាព និងផ្សារភ្ជាប់និរន្តរភាពអាស៊ាន៖

ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណ SDG នៅកម្ពុជាក៏នឹងទទួលបាននូវការលើកទឹកចិត្តផ្នែកពន្ធជាពិសេសបន្ថែមលើការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ការបោះផ្សាយសញ្ញាបណ្ណធម្មតាដែលកំពុងអនុវត្តដែលរួមមាន៖ ការកាត់បន្ថយពន្ធលើប្រាក់ចំណេញ ៥០% សម្រាប់ក្រុមហ៊ុនដែលបោះផ្សាយមូលបត្របំណុលក្នុងទំហំលើសពី ២០% នៃទ្រព្យសកម្មសរុប ឬ ៨ប៊ីលានរៀល (ឬប្រហែល ២លានដុល្លារអាមេរិក) សម្រាប់ក្រុមហ៊ុនដែលបោះផ្សាយមូលបត្របំណុលក្នុងចំនួនទឹកប្រាក់ស្មើនឹង ឬតិចជាង ២០% នៃទ្រព្យសកម្មសរុបសម្រាប់រយៈពេល ៣ឆ្នាំ និងការលើកលែងបំណុលពន្ធ (សម្រាប់ N-3 ដល់ N-10 ឆ្នាំសម្រាប់សហគ្រាសដែលចុះបញ្ជីនៅទីផ្សារគោលនៅផ្សារមូលបត្រកម្ពុជា និងសម្រាប់ N-2 ដល់ N-10 ឆ្នាំសម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលចុះបញ្ជីក្នុងទីផ្សារកំណើននៅផ្សារមូលបត្រកម្ពុជា)។

លើសពីនេះទៅទៀត ដៃគូអភិវឌ្ឍអន្តរជាតិដូចជា ADB ក៏មានផ្តល់ជាជំនួយបច្ចេកទេសដល់ស្ថាប័នដែលមានចំណាប់អារម្មណ៍បោះផ្សាយសញ្ញាបណ្ណ SDG ឬសញ្ញាបណ្ណដែលដាក់ស្លាកនិរន្តរភាព (Sustainable-labeled)។

ន.ម.ក រីករាយក្នុងការភ្ជាប់ស្ថាប័នដែលមានចំណាប់អារម្មណ៍បោះផ្សាយ ជាមួយនឹង ADB ដើម្បីពិភាក្សាពាក់ព័ន្ធនឹងជំនួយបច្ចេកទេសនេះ។ ម៉្យាងវិញទៀត ការបោះផ្សាយសញ្ញាបណ្ណបៃតងនៅកម្ពុជាក៏នឹងត្រូវដាក់ស្លាកជាសញ្ញាបណ្ណបៃតងអាស៊ាន ដែលមានន័យថាយើងអនុវត្តតាមស្តង់ដាអាស៊ាន ដូច្នេះវិនិយោគិនអាចវិនិយោគលើសញ្ញាបណ្ណបៃតងនៅក្នុងប្រទេសកម្ពុជាប្រកបដោយទំនុកចិត្ត។

ការវិនិយោគលើសញ្ញាបណ្ណបៃតងនៅកម្ពុជា វិនិយោគិននឹងទទួលបានការលើកទឹកចិត្តផ្នែកពន្ធពីរដ្ឋាភិបាលកម្ពុជារយៈពេល ៣ឆ្នាំ ដែលរាប់បញ្ចូលការកាត់បន្ថយពន្ធកាត់ទុក ៥០% និងការលើកលែងពន្ធលើចំណេញមូលធន៕ ■